# 10th Year´ Anniversary of Landmine Clearance Incident which killed 7 CMAC deminers ( 19 Jan 2007- 19 Jan 2017 )

ថ្ងៃទី១៩ខែមករាឆ្នាំ០១៧នេះ គឺជាខួបគម្រប់១០ឆ្នាំគត់(១៩ មករា ២០០៧-១៩ មករា ២០១៧) នៃការគ្រោះថ្នាក់ដោយសារគ្រាប់មីនតោនដាក់បង្កៃ ដែលបានធ្វើឱយអ្នកដោះមីនស៊ីម៉ាក់ចំនួន៧នាក់បានពលីជីវិត ដោយក្នុងនោះរួមមានប្រធានកងអនុសេនាតូចមួយរូប មេពួក៣រូប និងអ្នកដោះមីន៣រូប ក្នុងចំណោមអ្នកពលី ទាំង៧រូបមានស្ត្រីចំនួន៣រូប។ ឧបរហេតុនេះបានកើតឡើងនៅភូមិតាសែន ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ តាមរបាយការណ៍ស៊ើបអង្កេតបាន










វាយតំលៃនិងសន្និដ្ឋានថា គ្រាប់មីនតោនបង្កៃនេះអាចមានចំនួនជាច្រើនគ្រាប់ដាក់ត្រួតលើគ្នា នេះជាបទពិសោធន៍ ដ៏ជូរចត់បំផុតរបស់អង្គភាពស៊ីម៉ាក់ដែលបានបាត់បង់មន្ត្រីអ្នកដោះមីនច្រើនបំផុតក្នុងពេលគ្រោះថ្នាក់កំពុងធ្វើប្រតិបត្តិការដោះគ្រាប់មីនតែមួយកន្លែង។ យើងខ្ញុំពិតជាមានការសោកស្តាយនឹងមោទនភាពចំពោះពួកគាត់ដែលបានធ្វើពលីកម្មក្នុងបុព្វហេតុសេចក្តីសុខ សន្តិភាព សុវត្ថិភាពនេះ សូមឱយដួងព្រលឹងពួកគាត់ទាំងអស់គ្នាបានទៅដល់ឋានបរមសុខកុំបីខានឡើយ សូមរំលឹកថាកាលពីជាង១០ឆ្នាំមុន ស៊ីម៉ាក់បានកសាងគំរោងដោះមីនសហគមន៍នេះជាលើកទី១នៅឃុំតាសែន ព្រោះឃុំនេះជាឃុំដែលរងផលប៉ះពាល់បញ្ហាគ្រប់មីនយ៉ាងធ្ងន់ធ្ងរ និងអ្នករងគ្រោះដោយសារគ្រាប់មីន ច្រើនជាងគេទូទាំងប្រទេស ព្រមទាំងជាឃុំដែលមានអត្រាប្រជាពលរដ្ឋក្រីក្របំផុតច្រើនផងដែរ ភាគច្រើនជាជនចំណាកស្រុក ដែលទៅរកការងារធ្វើនៅប្រទេសថៃ។ ពេលនោះស៊ីម៉ាក់បានបង្កើតក្រុមដោះមីនសហគមន៍ជាពិសេស ដោយមានអ្នកដោះមីនជិត១០០នាក់ ដោយធ្វើការជ្រើសរើសនិងហ្វឹកហ្វឺននៅក្នុងឃុំ

តាសែននេះតែម្តង។ ស៊ីម៉ាក់បានខិតខំដោះមីនបណ្តើរ កៀរគរកជំនួយអភិវឌ្ឍន៍បណ្តើរដូចជាការកសាងសាលារៀន ជីកស្រះទឹក អណ្តូងទឹក និងជាពិសេស ការវិនិយោគខ្នាតតូចមធ្យមក្នុងការកសាងរោងចក្រក្នុងមូលដ្ឋាននេះ។ បច្ចុប្បន្ននៅក្នុងដែនភូមិសាស្ត្រឃុំតាសែន គ្មានការគ្រោះថ្នាក់ដោយសារគ្រាប់មីនទៀតទេ តំបន់ដែលគ្រាប់មីននៅសល់ គឺស្ថិតនៅតាមខ្សែរបន្ទាត់ព្រំដែនជាមួយប្រទេសថៃ។ ឃុំតាសែនបច្ចុប្បន្ន មានការរីកចំរើនយ៉ាងខ្លាំងក្លា ដែលពីមុនមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ឥឡូវមានផ្ទះថ្មធំតូចរីកដុះដាល ទីផ្សារមានមនុស្សម្នាយ៉ាងមមាញឹក ចំការតំឡូង ពោតសណ្តែក និងដំណាំយុទ្ធសាស្ត្រ ចពការស្វាយ មាន ជាដើម មើលទៅស្រស់បំព្រង ប្រៀបដូចទីវាលចំការនៅប្រទេសជឿនលឿនដូចឆ្នេះដែរ នេះគឺជាការប្រែក្លាយពីតំបន់សមភូមិសង្គ្រាម ចំការមីនមកជាតំបន់សន្តិភាពនិងការអភិវឌ្ឍន៍ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

Today 19 Jan 2017, is 10th year anniversary of landmine clearance incident (19 Jan 2007- 19 Jan 2017) which killed 7 CMAC deminers (one platoon commander, 3 sector commanders and 3 deminers) caused by anti tank landmines with booby trap. This incident was taken place at Tasen Commune, Kamrieng district, Battambang province and this commune was one of the heaviest landmine contaminated areas in this Kingdom. CMAC has promoted a community base demining in 2002 and recruited around 100 deminers from local people who were poorest, high risk and landmine affected families. We are very proud as Tasen commune now reached landmine impact free and this commune has made a remarkable development!




